ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ៖ បព ៤៩/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋកូរ៉េលើកទី២៦ កិច្ចប្រជុំកំពូលអាស៊ានបូកបីលើកទី២៨ កិច្ចប្រជុំថ្នាក់ដឹកនាំនៃភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់លើកទី៥ កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី២០ និងកិច្ចប្រជុំកំពូលអាស៊ាន-អង្គការសហប្រជាជាតិលើកទី១៥

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៥ ទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋកូរ៉េលើកទី២៦ កិច្ចប្រជុំកំពូលអាស៊ានបូកបីលើកទី២៨ កិច្ចប្រជុំថ្នាក់ដឹកនាំនៃភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់លើកទី៥ កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី២០ និងកិច្ចប្រជុំកំពូលអាស៊ាន-អង្គការសហប្រជាជាតិលើកទី១៥។

## ១. កិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋកូរ៉េលើកទី២៦

ថ្នាក់ដឹកនាំបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នា ដើម្បីពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយដែលផ្តោតលើអនាគត តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃផែនការសកម្មភាពអាស៊ាន-សាធារណរដ្ឋកូរ៉េ (ឆ្នាំ២០២៦-២០៣០) ដែលស្របតាមចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០៤៥។ ថ្នាក់ដឹកនាំបានគូសបញ្ជាក់ពីសារៈសំខាន់នៃការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច តាមរយៈកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-សាធារណរដ្ឋកូរ៉េ (AKFTA) និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)។ ថ្នាក់ដឹកនាំអាស៊ានក៏បានស្វាគមន៍ចំពោះការបន្តគាំទ្ររបស់សាធារណរដ្ឋកូរ៉េ សម្រាប់របៀបវារៈឌីជីថល ជាពិសេសកិច្ចព្រមព្រៀងក្របខ័ណ្ឌសេដ្ឋកិច្ចឌីជីថលអាស៊ាន (DEFA)។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី**បានថ្លែងអំណរគុណចំពោះការគាំទ្ររបស់សាធារណរដ្ឋកូរ៉េលើបរិវត្តកម្មឌីជីថលអាស៊ាន រួមមានតាមរយៈគម្រោងនវានុវត្តន៍ឌីជីថលអាស៊ាន-សាធារណរដ្ឋកូរ៉េ និងបានស្វាគមន៍ចំពោះគំនិតផ្តួចផ្តើមបង្កើតបណ្ឌិតសភាឌីជីថលអាស៊ាន-សាធារណរដ្ឋកូរ៉េ នៅកម្ពុជា ដែលនឹងបំពាក់បំប៉នប្រជាជននូវជំនាញដែលត្រៀមរួចជាស្រេចសម្រាប់ពេលអនាគត ជំរុញការច្នៃប្រឌិត និងពង្រឹងភាពជាដៃគូសម្រាប់អនាគតឌីជីថលដែលរឹងមាំ។ **សម្តេចធិបតី**ក៏បានលើកឡើងពីការរួមចំណែករបស់សាធារណរដ្ឋកូរ៉េក្នុងការជំរុញបណ្តាញអគ្គីសនីអាស៊ានឆ្នាំ២០៤៥ និងការលើកកម្ពស់កំណើននៃឧស្សាហកម្មច្នៃប្រឌិតរបស់អាស៊ាន។

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

**សម្តេចធិបតី**បានសង្កត់ធ្ងន់បន្ថែមលើសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការតំបន់កាន់តែរឹងមាំ ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន រួមមានការជួញដូរ ការរត់ពន្ធ ឧក្រិដ្ឋកម្មសាយប័រ ភេរវកម្ម និងការឆបោកតាមប្រព័ន្ធអ៊ីនធើណែត តាមរយៈការពង្រឹងការអនុវត្តច្បាប់ ការចែករំលែកព័ត៌មាន និងការកសាងសមត្ថភាព។ នៅក្នុងក្របខ័ណ្ឌទំនាក់ទំនងទ្វេភាគី អគ្គស្នងការនគរបាលជាតិកម្ពុជាបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយសមភាគីសាធារណរដ្ឋកូរ៉េ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយនូវការគំរាមកំហែងទាំងនេះ និងធានាបាននូវតំបន់ដែលមានសន្តិភាព សន្តិសុខ និងភាពធន់ ដែលធានាបាននូវសុវត្ថិភាព និងសុខុមាលភាពរបស់ប្រជាជនទាំងអស់គ្នា។

## ២. កិច្ចប្រជុំកំពូលអាស៊ានបូកបីលើកទី២៨

ថ្នាក់ដឹកនាំបានពិនិត្យឡើងវិញនូវទស្សនវិស័យសេដ្ឋកិច្ចក្នុងតំបន់ និងបានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការជំរុញកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅ ដើម្បីទាញយកអត្ថប្រយោជន៍ពីប្រព័ន្ធពាណិជ្ជកម្មពហុភាគីនិយមដែលបើកចំហ តម្លាភាព និងផ្អែកលើវិធានច្បាប់។ ថ្នាក់ដឹកនាំក៏បានបានគូសបញ្ជាក់អំពីសារៈសំខាន់នៃការពង្រឹងការរួបរួមគ្នា និងកិច្ចសហប្រតិបត្តិការតំបន់ក្នុងការដោះស្រាយបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាកាន់តែខ្លាំងឡើង ស្របជាមួយនឹងការរក្សាបាននូវតួនាទីស្នូលរបស់អាស៊ាននៅក្នុងដំណើរវិវឌ្ឍន៍នៃនិម្មាបនកម្មតំបន់ដែលដឹកនាំដោយអាស៊ាន ដើម្បីលើកកម្ពស់បរិយាបន្ន ចីរភាព ការអភិវឌ្ឍ និងវិបុលភាព។ ក្នុងន័យនេះ កិច្ចប្រជុំកំពូលបានអនុម័តសេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំអាស៊ានបូកបីស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងតំបន់។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ឡើងវិញនូវតួនាទីដ៏សំខាន់នៃកិច្ចសហប្រតិបត្តិការអាស៊ានបូកបី ក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍនៅក្នុងតំបន់អាស៊ីបូព៌ា។ **សម្តេចធិបតី** ក៏បានលើកបន្ថែមអំពីសារៈសំខាន់នៃការទាញយកអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ដែលមានស្រាប់ រួមមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានជាមួយប្រទេសបូកនីមួយៗ (FTA+1) និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) ដែលពង្រឹងដល់ប្រព័ន្ធពាណិជ្ជកម្មពហុភាគីនិយមដែលបើកចំហ និងផ្អែកលើវិធានច្បាប់ ដោយមានអង្គការពាណិជ្ជកម្មពិភពលោកជាស្នូល ដើម្បីជាប្រយោជន៍រួមសម្រាប់ប្រជាជនយើងទាំងអស់គ្នា។

ស្របជាមួយគ្នានឹងការស្វាគមន៍នូវការពង្រឹងយន្តការថ្មីៗនៃគំនិតផ្តួចផ្តើមឈៀងម៉ៃស្តីពីពហុភាគីនិយម (CMIM) ដែលជាគន្លឹះចម្បងក្នុងការគាំពារហិរញ្ញវត្ថុក្នុងតំបន់ **សម្តេចធិបតី** បានគូសបញ្ជាក់អំពីកាលានុវត្តភាពសំខាន់ៗនៃសេដ្ឋកិច្ចឌីជីថល និងកិច្ចព្រមព្រៀងក្របខ័ណ្ឌសេដ្ឋកិច្ចឌីជីថល (DEFA) ដែលជាកម្លាំងចលករនៃកំណើនឌីជីថលក្នុងតំបន់។ **សម្តេចធិបតី** ក៏បានសង្កត់ធ្ងន់បន្ថែមអំពីសារៈសំខាន់ក្នុងការពង្រឹងកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន និងការពង្រឹងការគ្រប់គ្រងបន្ទាត់ព្រំដែន តាមរយៈយន្តការដែលមានស្រាប់ ដែលស្ថិតក្រោមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់រដ្ឋមន្ត្រីអាស៊ានបូកបីស្តីពីឧក្រិដ្ឋកម្មឆ្លងដែន(AMMTC+3)។

## ៣. កិច្ចប្រជុំថ្នាក់ដឹកនាំនៃភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) លើកទី៥

ថ្នាក់ដឹកនាំបានគូសបញ្ជាក់ពីតួនាទីដ៏សំខាន់នៃកិច្ចព្រមព្រៀង RCEP ក្នុងការជំរុញសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងបង្កើនភាពធន់ស្របពេលនៃការកើនឡើងនូវភាពមិនប្រាកដប្រជារបស់សកលលោក។ ថ្នាក់ដឹកនាំអាស៊ានបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ខ្លួន ចំពោះការអនុវត្តកិច្ចព្រមព្រៀង RCEP ឱ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដោយធានាទីផ្សារបើកចំហ និងសច្ចាប្រណិធានបាន

ការកាត់បន្ថយរបាំងពាណិជ្ជកម្មដែលមិនចាំបាច់ និងការធ្វើឱ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្មនិងវិនិយោគនៅទូទាំងតំបន់។

ថ្នាក់ដឹកនាំបានយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះកិច្ចព្រមព្រៀង RCEP ដែលជាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA) ធំជាងគេបំផុតនៅលើពិភពលោក ដែលមានទីផ្សារប្រមាណ ១ភាគ៣នៃចំនួនប្រជាជននិងផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក និងបានបង្ហាញពីមហិច្ឆតាបន្ថែមទៀតក្នុងការប្រើប្រាស់ការពិនិត្យឡើងវិញទូទៅនៃកិច្ចព្រមព្រៀង RCEP ដែលគ្រោងនឹងធ្វើឡើងនៅឆ្នាំ២០២៧ ដើម្បីធ្វើឱ្យ RCEP ក្លាយទៅជាកិច្ចព្រមព្រៀងដែលទំនើប រស់រវើក និងមានស្តង់ដាខ្ពស់ ដោយរួមបញ្ចូលបទប្បញ្ញត្តិលើបញ្ហាសម័យទំនើប និងដែលកំពុងលេចឡើង រួមមានសេដ្ឋកិច្ចបៃតង និងសេដ្ឋកិច្ចឌីជីថល ជាដើម។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា RCEP គឺជានិមិត្តរូបនៃការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជាចំពោះពាណិជ្ជកម្មដែលមានមូលដ្ឋានលើច្បាប់ និងជាឧទាហរណ៍នៃតំបន់និយមបើកចំហ ដែលផ្អែកលើមជ្ឈភាពអាស៊ាន។ **សម្តេចធិបតី** បានសម្តែងការគាំទ្រយ៉ាងខ្លាំងចំពោះការពន្លឿនការចូលជាភាគីថ្មីរបស់ RCEP ស្របតាមនីតិវិធីដែលបានព្រមព្រៀងគ្នា ដោយសង្កត់ធ្ងន់ថា ការពង្រីកសមាជិកភាពរបស់កិច្ចព្រមព្រៀង RCEP នឹងបង្កើនភាពជឿជាក់និងបរិយាបន្នរបស់កិច្ចព្រមព្រៀង ដែលជាកម្លាំងចលករដ៏សំខាន់នៃកំណើនប្រកបដោយចីរភាពនិងស្ថិរភាពក្នុងតំបន់។

## ៤. កិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី២០

ថ្នាក់ដឹកនាំបានគូសបញ្ជាក់ពីតួនាទីដ៏សំខាន់នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ដែលជាវេទិការបស់ថ្នាក់ដឹកនាំកំពូលសម្រាប់កិច្ចសន្ទនាជាយុទ្ធសាស្ត្រ និងកិច្ចសហប្រតិបត្តិការ ក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់។ ថ្នាក់ដឹកនាំបានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការពង្រឹងបន្ថែមទៀតនូវការអនុវត្តផែនការសកម្មភាពនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា (ឆ្នាំ២០២៤-២០២៨) តាមរយៈកិច្ចសហប្រតិបត្តិការជាក់ស្តែង ដើម្បីធានាបាននូវភាពពាក់ព័ន្ធ និងប្រសិទ្ធភាព នៅក្នុងនិម្មាបនកម្មតំបន់ និងនៅចំពោះការវិវឌ្ឍយ៉ាងឆាប់រហ័សនៃសកលលោក។ ថ្នាក់ដឹកនាំក៏បានផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងអន្តរជាតិដែលជាផលប្រយោជន៍និងកង្វល់រួម ក្នុងគោលដៅលើកកម្ពស់ទំនុកចិត្ត និងការយោគយល់គ្នាទៅវិញទៅមកក្នុងការដោះស្រាយបញ្ហាប្រឈមរួមគ្នា នាពេលខាងមុខ។ ក្នុងឱកាសរំឭកខួបលើកទី២០ នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ថ្នាក់ដឹកនាំបានអនុម័តសេចក្តីថ្លែងការណ៍ទីក្រុងគូឡាឡាំពួស្តីពីខួបលើកទី២០ នៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងសេចក្តីប្រកាសរបស់ថ្នាក់ដឹកនាំនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាស្តីពីការលើកកម្ពស់ការបញ្ជ្រាបដល់ថ្នាក់មូលដ្ឋានក្នុងការត្រៀមខ្លួនការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា កិច្ចប្រជុំកំពូលអាស៊ីបូព៌ាមានសក្តានុពលដ៏ធំធេងសម្រាប់កិច្ចសហប្រតិបត្តិការលើផ្នែកសេដ្ឋកិច្ច និងវិបុលភាពរួម ជាពិសេសក្នុងវិស័យដែលកំពុងរីកចម្រើនដូចជាសេដ្ឋកិច្ចឌីជីថល អន្តរកាលបៃតង សេដ្ឋកិច្ចពណ៌ខៀវ ខ្សែសង្វាក់ផ្គត់ផ្គង់ វិទ្យាសាស្ត្រ និងនវានុវត្តន៍។ **សម្តេចធិបតី** បានអះអាងពីសារៈសំខាន់នៃការលើកកម្ពស់សន្តិភាព សន្តិសុខ និងវិបុលភាព ដែលត្រូវតែជំរុញឡើង តាមរយៈការទូត កិច្ចសន្ទនា និងការគោរពច្បាប់អន្តរជាតិ ហើយក៏បានបញ្ជាក់ជាថ្មីអំពីការប្រកាន់ខ្ជាប់យ៉ាងមុឹងម៉ាត់របស់កម្ពុជា ចំពោះអំពើអហិង្សា សន្តិសហវិជ្ជមាន និងការគោរពអធិបតេយ្យ និងបូរណភាពទឹកដីនៃរដ្ឋទាំងឡាយ។

**សម្តេចធិបតី** ក៏បានគូសបញ្ជាក់ថា ការចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍ទីក្រុងគូឡាឡាំពួររវាងកម្ពុជានិងថៃ គឺជាព្រឹត្តិការណ៍ដ៏សំខាន់មួយ ដែលបានបង្ហាញនូវសក្ខីភាពដ៏មានឥទ្ធិពល សូម្បីតែជម្លោះដ៏

លំបាកបំផុតក៏អាចត្រូវបានដោះស្រាយតាមរយៈការគោរពគ្នាទៅវិញទៅមក ការអត់ធ្មត់ និងតាមរយៈការទូត។ ភាពជោគជ័យនេះគឺជាលទ្ធផលនៃបទឈប់បាញ់ដែលប្រទេសទាំងពីរបានខិតខំប្រឹងប្រែងបង្កើត និងប្រកាន់យ៉ាងខ្ជាប់ខ្ជួន ដោយមានការចូលរួមគាំទ្រពីដៃគូទាំងឡាយ។ **សម្តេចធិបតី** បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះ**ម៉ាឡេស៊ី**ក្នុងការសម្របសម្រួលកិច្ចសន្ទនាដោយផ្ទាល់ និងប្រកបដោយភាពស្ថាបនា, និងចំពោះ**សហរដ្ឋអាមេរិក**ក្នុងការជំរុញឱ្យមានការបញ្ឈប់អរិភាព និងការគាំទ្រឱ្យមានកិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់, និង**ចិន**ចំពោះការរៀបចំកិច្ចសន្ទនាក្រៅផ្លូវការជាបន្តបន្ទាប់ ក្នុងគោលដៅលើកកម្ពស់ការស្វែងយល់ដឹងពីគ្នា និងជំរុញឱ្យមានការដោះស្រាយដោយសន្តិវិធី។

## ៥. កិច្ចប្រជុំកំពូលអាស៊ាន-អង្គការសហប្រជាជាតិលើកទី១៥

ថ្នាក់ដឹកនាំអាស៊ាននិងអង្គការសហប្រជាជាតិ បានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការពង្រឹងភាពជាដៃគូគ្រប់ជ្រុងជ្រោយ ក្រោមផែនការសកម្មភាពសម្រាប់ការអនុវត្តសេចក្តីប្រកាសរួមស្តីពីភាពជាដៃគូគ្រប់ជ្រុងជ្រោយអាស៊ាន-អង្គការសហប្រជាជាតិ (ឆ្នាំ២០២៦-២០៣០) ដែលទើបបានអនុម័តនាពេលថ្មីនេះ។ កិច្ចប្រជុំកំពូលបានគូសបញ្ជាក់ពីកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងការបន្សុីគ្នារវាងផែនការសកម្មភាពនេះទៅនឹងទស្សនវិស័យអាស៊ានឆ្នាំ២០៤៥ និងរបៀបវារៈស្តីពីការការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជាចំពោះសន្តិភាព ពហុភាគីនិយម និងគោលការណ៍នានានៃធម្មនុញ្ញអង្គការសហប្រជាជាតិ។ **សម្តេចធិបតី**បានគូសបញ្ជាក់ថាពុំមានប្រទេសណាមួយមានលទ្ធភាពប្រឈមមុខនឹងបញ្ហាដ៏ស្មុគស្មាញនាពេលបច្ចុប្បន្ន តែម្នាក់ឯងនោះទេ និងបានអំពាវនាវឱ្យប្រកាន់យកនូវស្មារតីទំនួលខុសត្រូវរួម ក្នុងការលើកកម្ពស់នូវតួនាទីស្នូលរបស់អង្គការសហប្រជាជាតិ ក្នុងការកសាងពិភពលោកឱ្យមានសន្តិភាព ស្ថិរភាព និងយុត្តិធម៌ កាន់តែប្រសើរ។ **សម្តេចធិបតី** បានសង្កត់ធ្ងន់ថា អាស៊ានស្ថិតក្នុងចំណោមតំបន់ដែលមានកំណើតយ៉ាងឆាប់រហ័សរបស់សកលលោក។ ប៉ុន្មានឆ្នាំចុងក្រោយនេះ អាស៊ានបានខិតខំកាន់តែខ្លាំងមិនត្រឹមតែដើម្បីសម្រេចបាននូវកំណើនដ៏ឆាប់រហ័សប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាបានថា កំណើននេះគឺប្រកបដោយចីរភាព បរិយាបន្ន និងរឹងមាំ។ អាទិភាពទាំងអស់នេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងឯកសារចក្ខុវិស័យអាស៊ានឆ្នាំ២០៤៥៖ អនាគតរួមគ្នា ដែលបានដាក់ចេញនូវទិសដៅសម្រាប់កិច្ចខិតខំរួមគ្នារបស់អាស៊ាន ឆ្ពោះទៅសម្រេចបានជាតំបន់មួយដែលប្រកបដោយព័ណ៌បៃតង ចីរភាព និងសមភាព កាន់តែល្អប្រសើរជាងមុន។

## ៦. ជំនួបទ្វេភាគីរបស់សម្តេចធិបតីនាយករដ្ឋមន្ត្រី

### ១. នូវែលសេឡង់

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាទ្វេភាគីជាមួយ**ឯកឧត្តម** Christopher Luxon នាយករដ្ឋមន្ត្រីនូវែលសេឡង់ ដែលក្នុងឱកាសនោះ**សម្តេចធិបតី**បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការល្អរវាងកម្ពុជា និងនូវែលសេឡង់។ **សម្តេចធិបតី**បានជម្រាបជូនអំពីស្ថានភាពនៃការអភិវឌ្ឍ និងអាទិភាពសេដ្ឋកិច្ចកម្ពុជា ក្នុងនោះរួមមានការធ្វើពិពិធកម្មទៅលើទីផ្សារនាំចេញ និងប្រភេទផលិតផលសម្រាប់នាំចេញផងដែរ។ **សម្តេចធិបតី**បានគូសបញ្ជាក់អំពីកាលានុវត្តភាពក្នុងការបង្កើនទំហំពាណិជ្ជកម្មទ្វេភាគី ដោយកម្ពុជាមានសក្តានុពលជាច្រើនក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី និងពហុភាគីនានា។ ក្នុងន័យនេះ **សម្តេចធិបតី** បានស្នើនាយករដ្ឋមន្ត្រីនូវែលសេឡង់ជួយជំរុញវិនិយោគិននូវែលសេឡង់ពិនិត្យលទ្ធភាពធ្វើការវិនិយោគនៅកម្ពុជាឱ្យបានច្រើន។ **ឯកឧត្តម** Christopher Luxon បានលើកឡើងថា កម្ពុជា

និងនូវែលសេឡង់មានភាពខ្លាំងរៀងៗខ្លួនដែលអាចបំពេញឱ្យគ្នាទៅវិញទៅមក ព្រមទាំងឯកភាពគ្នាបន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគីបន្ថែមទៀត ជាពិសេសលើវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម។ **នាយករដ្ឋមន្ត្រីនូវែលសេឡង់**បានថ្លែងអរគុណកម្ពុជា ដែលបានគាំទ្រដល់ការបង្កើតភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ អាស៊ាន-នូវែលហ្សេឡង់។ **ថ្នាក់ដឹកនាំទាំងពីរ**ក៏បានផ្លាស់ប្តូរទស្សនៈគ្នាទៅលើបញ្ហាតំបន់ និងពិភពលោកមួយចំនួន រួមទាំងបញ្ហាពន្ធគយរបស់អាមេរិក។

### ២. អូស្ត្រាលី

**សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាទ្វេភាគីជាមួយ**ឯកឧត្តម** Anthony Albanese នាយករដ្ឋមន្ត្រីអូស្ត្រាលី ដែលនាយករដ្ឋមន្ត្រីទាំងពីរបានវាយតម្លៃខ្ពស់ចំពោះការរីកចម្រើននៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អរវាងកម្ពុជា និងអូស្ត្រាលី នៅក្នុងវិស័យពាណិជ្ជកម្ម និងសេដ្ឋកិច្ច សន្តិសុខ និងការពារជាតិ ព្រមទាំងការផ្លាស់ប្តូរប្រជាជននិងប្រជាជន នាពេលកន្លងមក។ **សម្តេចធិបតី**បានគូសបញ្ជាក់ថា ទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរមានការកើនឡើងប្រមាណ ៦០០លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២៤ ដូចនេះ ប្រទេសទាំងពីរគួរបង្កើនដល់ទំហំ ១,០០០លានដុល្លារ និងបានវាយតម្លៃខ្ពស់ចំពោះតួនាទីអូស្ត្រាលី ក្នុងការរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា ដោយថ្មីៗនេះបានបង្កើនចំនួនអាហារូបករណ៍ សម្រាប់និស្សិតកម្ពុជាពី ៥០កន្លែង ឡើងដល់ ៦២កន្លែង សម្រាប់ឆ្នាំ២០២៥ តបតាមសំណើរបស់**សម្តេចធិបតី**។ **សម្តេចធិបតី**ក៏បានកត់សម្គាល់វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក្នុងវិស័យការពារជាតិ និងសន្តិសុខ ដោយនាវាចម្បាំង HMAS Ballarat របស់កងទ័ពជើងទឹកអូស្ត្រាលី បានចូលចតនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងបានបំពេញទស្សនកិច្ចនៅមូលដ្ឋានសមុទ្ររាម កាលពីពាក់កណ្តាលខែតុលា ឆ្នាំ២០២៥ កន្លងទៅ។ **ឯកឧត្តម** Anthony Albanese បានរំឭកអំពីដំណើរទស្សនកិច្ចរបស់ឯកឧត្តមនៅកម្ពុជាកន្លងមក ដោយបានចាប់អារម្មណ៍លើសក្តានុពលរបស់កម្ពុជា ក្នុងវិស័យទេសចរណ៍ផងដែរ។ **ឯកឧត្តម** Anthony Albanese ក៏បានវាយតម្លៃខ្ពស់ចំពោះកិច្ចប្រឹងប្រែងរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មសាយប័រ និងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ដោយបានចាត់ទុកបញ្ហាទាំងនេះជាបញ្ហាប្រឈមសម្រាប់ប្រទេសទាំងអស់។ **នាយករដ្ឋមន្ត្រីអូស្ត្រាលី**ក៏បានស្វាគមន៍ការវិវឌ្ឍវិជ្ជមានចំពោះដំណោះស្រាយបញ្ហាជម្លោះព្រំដែនរវាងប្រទេសកម្ពុជានិងថៃ និងបានវាយតម្លៃខ្ពស់អំពីភាពជាអ្នកដឹកនាំដ៏ប៉ិនប្រសប់របស់**សម្តេចធិបតី** ក្នុងដំណើរការស្វែងរកដំណោះស្រាយលើបញ្ហានេះ។ **នាយករដ្ឋមន្ត្រីទាំងពីរ**ក៏បានឯកភាពក្នុងការបន្តពង្រឹង និងពង្រីកនូវកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងអូស្ត្រាលីឱ្យកាន់តែរីកចម្រើនថែមទៀត។

## ៧. ជំនួបទ្វេភាគីរបស់ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី

### ១. ទីម័រឡេស្តេ

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានជួបពិភាក្សាជាមួយ**ឯកឧត្តមបណ្ឌិត** Bendito dos Santos Freitas រដ្ឋមន្ត្រីការបរទេស និងកិច្ចសហប្រតិបត្តិការនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ដែលក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានសម្តែងនូវការអបអរសាទរយ៉ាងស្មោះអស់ពីដួងចិត្តចំពោះទីម័រឡេស្តេ ដែលបានចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ាន និងមានជំនឿយ៉ាងមុតមាំថា នេះជាព្រឹត្តិការណ៍ដ៏សំខាន់ ដែលនឹងពង្រឹងបន្ថែមនូវសាមគ្គីភាពគ្នាក្នុងតំបន់ និងដំណើររួមគ្នាឆ្ពោះទៅកាន់សហគមន៍អាស៊ានប្រកបដោយបរិយាបន្ន ភាពធន់ និងវិបុលភាព។ **ឯកឧត្តមបណ្ឌិត** Freitas បានពាំនាំនូវការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅរបស់ទីម័រឡេស្តេចំពោះកម្ពុជា សម្រាប់ការគាំទ្រនិងការរួមចំណែកដ៏ធំធេងដល់ការចូលជាសមាជិកពេញសិទ្ធិអាស៊ានរបស់ទីម័រឡេស្តេ និងបានសម្តែងការអបអរសាទរដោយស្មោះត្រង់ដល់កម្ពុជា ចំពោះការចុះហត្ថលេខា

លើសេចក្តីថ្លែងការណ៍រួមគួឡាឡាំពួ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។ **រដ្ឋមន្ត្រីទាំងពីរ**ក៏បានពិភាក្សាគ្នាលើទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា និងទីម័រឡេស្តេ ព្រមទាំងបានផ្លាស់ប្តូរយោបល់គ្នាលើកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ានផងដែរ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានបញ្ជាក់សាជាថ្មីនូវការបន្តគាំទ្ររបស់កម្ពុជាតាមលទ្ធភាពរបស់ខ្លួនដល់ទីម័រឡេស្តេ នៅជំហានបន្ទាប់ក្នុងនាមជារដ្ឋសមាជិកអាស៊ាន។

២. វៀតណាម

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**ឯកឧត្តម** Le Hoai Trung បានជួបពិភាក្សាទ្វេភាគីជាលើកដំបូងជាមួយ**ឯកឧត្តម** Le Hoai Trung ក្នុងតួនាទីថ្មីរបស់គាត់ជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ **រដ្ឋមន្ត្រីទាំងពីរ**បានត្រៀមខ្លួននឹងធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធ ដើម្បីរួមចំណែកធ្វើឱ្យទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរកាន់តែស៊ីជម្រៅថែមទៀត។ **ឯកឧត្តម** Le Hoai Trung បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះ**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** សម្រាប់ពាក្យពេចន៍អបអរសាទរ និងបានសម្តែងនូវអបអរសាទរយ៉ាងស្មោះស្ម័គ្រចំពោះការចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមគួឡាឡាំពួ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និង**ឯកឧត្តម** Le Hoai Trung បានកោតសរសើរយ៉ាងក្រៃលែងចំពោះភាពរីកចម្រើននៃកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់ជាញឹកញាប់រវាងថ្នាក់ដឹកនាំទាំងពីរ។ **រដ្ឋមន្ត្រីការបរទេសទាំងពីរ**បានផ្លាស់ប្តូរទស្សនៈលើវិស័យសំខាន់ៗនៃកិច្ចសហប្រតិបត្តិការទៅវិញទៅមក រួមមានលើវិស័យពាណិជ្ជកម្ម ការវិនិយោគ ការផ្លាស់ប្តូរប្រជាជននិងប្រជាជន និងការតភ្ជាប់។ **ថ្នាក់ដឹកនាំទាំងពីរ**ក៏បានពិភាក្សាអំពីការត្រៀមរៀបចំកិច្ចប្រជុំលើកទី២១ នៃគណៈកម្មការចម្រុះរវាងកម្ពុជា និងវៀតណាម ដែលគ្រោងធ្វើនៅខែធ្នូ នៅកម្ពុជា។

៣. សហរដ្ឋអាម៉េរិក

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានជួបពិភាក្សាជាមួយ**លោកជំទាវ** Allison Hooker អនុរដ្ឋលេខាធិការនៃក្រសួងការបរទេសសហរដ្ឋអាម៉េរិក ដែលក្នុងឱកាសនោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានសម្តែងនូវការអរគុណដ៏ជ្រាលជ្រៅបំផុត ចំពោះកិច្ចខិតខំប្រឹងប្រែងដ៏គួរឱ្យស្ងើចសរសើររបស់សហរដ្ឋអាម៉េរិក ជាពិសេសភាពជាអ្នកដឹកនាំដ៏ម៉ឺងម៉ាត់ និងតួនាទីមិនអាចកាត់ថ្លៃបានរបស់**ឯកឧត្តមប្រធានាធិបតី ដូណាល់ ជេ. ត្រាំ (Donald J. Trump)** ក្នុងការសម្របសម្រួល ឱ្យមានកិច្ចព្រមព្រៀងបទឈប់បាញ់ និងការចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រវាងកម្ពុជា និងថៃ នៅប្រទេសម៉ាឡេស៊ី។ **លោកជំទាវ** Allison Hooker បានបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តដ៏មុតមាំរបស់សហរដ្ឋអាម៉េរិកក្នុងការគាំទ្រដល់ការអនុវត្តពេញលេញ និងប្រកបដោយប្រសិទ្ធភាពនៃកិច្ចព្រមព្រៀងសន្តិភាពរវាងកម្ពុជានិងថៃ រួមទាំងការដោះលែងទាហានកម្ពុជាទាំង១៨នាក់ភ្លាមៗផងដែរ។

**ភាគីទាំងពីរ**បានគូសបញ្ជាក់អំពីសារៈសំខាន់នៃឆ្នាំ២០២៥នេះ ដែលជាខួបលើកទី៧៥ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជានិងសហរដ្ឋអាម៉េរិក និងស្របពេលដែលកម្ពុជាបំពេញតួនាទីជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-អាម៉េរិក។ **ភាគីទាំងពីរ**បានស្វាគមន៍សន្ទុះជាវិជ្ជមាននៃទំនាក់ទំនងទ្វេភាគី និងបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នាក្នុងកាជំរុញកិច្ចសហប្រតិបត្តិការឈានទៅមុខលើគ្រប់វិស័យ ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក រួមមានពាណិជ្ជកម្ម វិនិយោគ កិច្ចសហប្រតិបត្តិការស្វែងរកអដ្ឋិធាតុទាហានអាម៉េរិកបាត់ខ្លួនក្នុងសម័យសង្គ្រាមនៅកម្ពុជា ការដោះមីន ការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរពីសហរដ្ឋអាម៉េរិក ការផ្លាស់ប្តូរវប្បធម៌ ការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជន រួមទាំងបញ្ហាសន្តសុខមិនមែនប្រពៃណី ។ល។

ចំពោះកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ភាគីទាំងពីរបានស្វាគមន៍ចំពោះការចុះហត្ថលេខានាពេលថ្មីៗនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មបដិការរវាងប្រទេសទាំងពីរ ដែលរំពឹងថានឹងជំរុញរំហូរពាណិជ្ជកម្ម និងការវិនិយោគទ្វេភាគី ព្រមទាំងបើកផ្លូវថ្មីសម្រាប់កិច្ចសហការពីវិស័យឯកជន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីពីការត្រៀមខ្លួនរបស់កម្ពុជាក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយសហរដ្ឋអាម៉េរិក ដើម្បីអនុវត្តឱ្យបានពេញលេញនូវកិច្ចព្រមព្រៀងនេះ និងស្វែងរកយន្តការបន្ថែម ដែលអាចពង្រឹងភាពធន់ខាងសេដ្ឋកិច្ច និងវិបុលភាពរួមគ្នាសម្រាប់ប្រជាជាតិទាំងពីរ។

ថ្ងៃអង្គារ ៧កើត ខែកត្ដិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០២៥